ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមព្រហ្មទណ្ឌ
លេខ ៥៣២ "ណ"
ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០២២
-សំណុំរឿងព្រហ្មទណ្ឌលេខ៥២៧
ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៨
-សំណុំរឿងស៊ើបសួរលេខ១៧៨៣
ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៨
-សំណុំរឿងជំនុំជម្រះលេខ១២៥០
ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៩

ក្នុងនាមប្រជារាស្ត្រខ្មែរ
សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជំនុំជម្រះជាសាធារណៈ នៅសាលាដំបូងរាជធានីភ្នំពេញ នាថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២២ វេលាម៉ោង ០២ និង៣០នាទីរសៀល ដោយមានសមាសភាពចូលរួមដូចតទៅ:

ចៅក្រមជំនុំជម្រះ

លោកស្រី [redacted] ចៅក្រម និងជាអនុប្រធានសាលាដំបូងរាជធានីភ្នំពេញ

តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

ក្រឡាបញ្ជីសវនាការ

កញ្ញា [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើបណ្តឹងទាស់របស់ពិរុទ្ធជនឈ្មោះ [redacted] ស្រួយ ហៅ មី ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២២ លើសាលក្រមព្រហ្មទណ្ឌលេខ២៤៦៧ "ណ" ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៩ នៃសំណុំរឿងព្រហ្មទណ្ឌលេខ៥២៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៨ ដែលមានពិរុទ្ធជនឈ្មោះ [redacted] ស្រួយ ហៅ មី ភេទប្រុស កើតថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៩៥ ជនជាតិខ្មែរ មុខរបរលក់ផ្លែឈើ ទីកន្លែងកំណើតនៅ [redacted] ខេត្តកំពង់ចាម ទីលំនៅបច្ចុប្បន្ន ស្នាក់នៅផ្ទះលេខ១៦៦ ក្នុងបុរីលីមឈាងហាក់ ផ្លូវលេខ០៦បេ ភូមិម័ល សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ប្រពន្ធឈ្មោះ [redacted] សូដានី "រ" មានកូន ០២នាក់ ឪពុកឈ្មោះ [redacted] ទី "រ" ម្តាយឈ្មោះ [redacted] សុគន្ធា "រ" ជានីតិជនទោសពីមុន-គ្មាន។

-ដីកាបង្គាប់ឲ្យចាប់ខ្លួន និងឃុំខ្លួនលេខ៦៥៧ "ណ" ដ.ច.ន ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៩។

-ចាប់ខ្លួនបាននៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០២២។

-ដីកាបង្គាប់ឲ្យដោះលែងលេខ៩៦៨ "ណ" ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២២។

ជាប់ចោទពីបទ: ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចក្នុងផ្សារនាគមាស ផ្លូវលេខ២៣៩ កែងផ្លូវ២៣៩ សង្កាត់ផ្សារដើមគរ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោស តាមមាត្រា២១៨ នៃក្រមព្រហ្មទណ្ឌ។

មានលោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិ មានការិយាល័យផ្ទះលេខ១៤៩E$_0$ ផ្លូវលេខ១៣៦ សង្កាត់ផ្សារកណ្តាល២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

មានលោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិ មានការិយាល័យលេខ៥១ ផ្លូវ៦០៨ សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] តាំ ភេទប្រុស អាយុ ២៣ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះលេខ៣៩MC14 សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

អត្ថហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៧ វេលាម៉ោង ០១ និង០០នាទី រំលងអាធ្រាត្រ ជនរងគ្រោះឈ្មោះ [redacted] តាំ ភេទប្រុស បានកំពុងរៀបផ្តែឈើលក់នៅផ្សារនាគមាស ខណ្ឌទួលគោក រាជធានីភ្នំពេញ ក្រោយពីរៀបចំកន្លែងលក់ហើយ ស្រាប់តែឈ្មោះ [redacted] ស្រួយ និងបក្ខពួកបានស្រែកមកកាន់ឈ្មោះ [redacted] តាំ ថាគ្មានភ្នែកមើលទេឬ បានជាដាក់ឥវ៉ាន់មិនដឹងកន្លែងគេកន្លែងឯងចឹង ពេលនោះក៏មានទំនាស់ពាក្យសំដីគ្នា ស្រាប់តែឈ្មោះ [redacted] ស្រួយ ហៅ មី និងបក្ខពួកបានយកខ្សែក្រវ៉ាត់ កៅអីស្ទុះមកវាយលើឈ្មោះ [redacted] តាំ ទាំងកំរោលបណ្តាលឱ្យជនរងគ្រោះបែកក្បាលហូរឈាម និងបែកបបូរមាត់ និងរងរបួសលើខ្លួនប្រាណ និងត្រង់ដៃ។

-បានឃើញ ពាក្យបណ្តឹង ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៨ របស់ឈ្មោះ [redacted] តាំ។

-បានឃើញ ដីកាសន្និដ្ឋានស្តាពរលេខ១១៣៦ អ.ឃ.ឃ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាសម្រេចលើកលែងចោទប្រកាន់លេខ១៥៣៩ "ឋ" ដ.ដ ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ១៥៤០ "ឋ" ដ.ដ ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ២៤៦៧ "ឈ" ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៩ របស់សាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ពាក្យសុំឱ្យមានការដោះលែងនៅក្រៅឃុំ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២២ របស់លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យពិរុទ្ធជន។

-បានឃើញ សាលក្រមមុនអង្គសេចក្តីលេខ០៨ "ឈ" ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ បណ្តឹងទាស់ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២២ របស់ពិរុទ្ធជនឈ្មោះ [redacted] ស្រួយ។

-បានឃើញ សេចក្តីចម្លងបណ្តឹងទាស់លេខ០២០ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ សេចក្តីចម្លងបណ្តឹងទាស់លេខ០២១ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ។

នាពេលសវនាការ

-ពិរុទ្ធជនឈ្មោះ [redacted] ស្រួយ ហៅ មី ឆ្លើយនាពេលសវនាការថា ខ្លួនសុំប្តឹងទាស់និងសេចក្តីសម្រេចទាំងមូលនៃសាលក្រមព្រហ្មទណ្ឌលេខ២៤៦៧ "ឈ" ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៩ របស់សាលាដំបូងរាជធានីភ្នំពេញ ដោយហេតុថារឿងហេតុដែលបណ្តាលឱ្យមានអំពើហិង្សានេះកើតឡើងដោយសារឈ្មោះ [redacted] តាំ បានវាយមកលើម្តាយរបស់ខ្លួនឈ្មោះ [redacted] លី មុនរហូតបណ្តាលឱ្យម្តាយរបស់ខ្លួនហើម និងជាំភ្នែក ដូចមានរូបថតដាក់ជូនជាភស្តុតាង។ ឈ្មោះ [redacted] តាំ ក៏ជាសាច់ញាតិរបស់ខ្លួនដែរគឺត្រូវជាបងប្អូនជីដូនមួយនឹងគ្នា។ នៅថ្ងៃដែលឈ្មោះ [redacted] តាំ វាយមកលើម្តាយរបស់ខ្លួនគឺខ្លួនមិន

Scanned with CamScanner

បានឃើញហេតុការជាក់ស្តែងនោះទេ តែមានអ្នកមកប្រាប់ខ្លួនទើបខ្លួនចូលទៅសួរនាំឈ្មោះ [redacted] តាំ ហើយក៏មានការទាស់សំដីគ្នា រួចឈ្មោះ [redacted] តាំ បានលោតមកវាយខ្លួនមុន ហើយក៏បានប្រតាយប្រតប់គ្នាទៅវិញទៅមកដោយដៃ និងដៃតែពីរនាក់ពុំមានអ្នកផ្សេងឡើយ។ ខ្លួនក៏ពុំមានកាន់ខ្សែក្រវ៉ាត់ ឬកៅអីអ្វីនោះទេ បន្ទាប់ពីប្រតាយប្រតប់គ្នាហើយក៏បែកគ្នារៀងខ្លួនដោយមិនមានអ្នកណាចូលមកឃាត់នោះទេ។ ចំពោះរបួសរបស់ឈ្មោះ [redacted] តាំ ខ្លួនពុំដឹងនោះទេ ព្រោះពេលប្រតាយប្រតប់គ្នាហើយខ្លួនក៏បានទៅផ្ទះពុំឃើញមានរបួសស្នាមទេ។

-តាមអំណានចម្លើយជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]តាំ បានឆ្លើយថា កាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៧ ម៉ោងប្រហែល ១រំលងអាធ្រាត្រ ខ្លួនកំពុងរៀបចំកន្លែងលក់ផ្លែឈើតែម្នាក់ឯង នៅក្នុងផ្សារនាគមាសផ្លូវ២៣៤ កែងផ្លូវ២៣៩ សង្កាត់ផ្សារដើមគរ ខណ្ឌទួលគោក រាជធានីភ្នំពេញ។ ក្រោយពីរៀបចំកន្លែងលក់រួចរាល់ហើយពេលនោះជនល្មើសឈ្មោះ [redacted]លី និងឈ្មោះ អ៊ត បាននិយាយស្រែកមកកាន់ខ្លួនថា គ្មានភ្នែកទេឬ? ដែលដាក់ឥវ៉ាន់មិនដឹងកន្លែងគេឯងចឹង? ពេលនោះខ្លួននិយាយទៅកាន់ពួកគេវិញថា ខ្លួនដាក់ឥវ៉ាន់នៅកន្លែងរបស់ខ្លួនមិនមែនដាក់នៅកន្លែងបងឯងទេ ហើយក៏មានការប្រកែកពាក្យសំដីគ្នា ហើយបានមួយសន្ទុះក៏ឈប់ប្រកែក រួចដើរទៅអង្គុយផឹកទឹក ស្រាប់តែជនដៃដល់ឈ្មោះ [redacted] ស្រួយ ហៅ មី និងបក្ខពួកបានប្រដាប់ដោយអាវុធមាន ខ្សែក្រវ៉ាត់ កៅអី បានស្ទុះមកធ្វើសកម្មភាពវាយមកលើរូបខ្លួនទាំងកំរោលបណ្តាលឲ្យខ្លួនបែកក្បាលហូរឈាម និងបែកបបូរមាត់ និងរងរបួសលើខ្លួនប្រាណ និងត្រង់ដៃយ៉ាងធ្ងន់ធ្ងរ ហើយដួលសន្លប់ទៅលើដី។ លុះពេលដែលដឹងខ្លួនឡើងវិញគឺកំពុងសម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យវិសាលសុខ។ ខ្លួនដេកព្យាបាលនៅពេទ្យ៥ថ្ងៃ ព្យាបាលអស់ប្រាក់ប្រហែល ៣,000(បីពាន់)ដុល្លារអាមេរិក និងបន្តព្យាបាលដល់បច្ចុប្បន្ននេះអស់ប្រាក់ប្រហែល៥,000(ប្រាំពាន់)ដុល្លារអាមេរិកទៀត។ គ្រួសាររបស់ជនល្មើសមួយនេះគឺតែងតែឈ្លោះរករឿងគេគ្រប់គ្នា។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា ក្រោយពីបានស្តាប់ការសួរដេញដោលនាពេលសវនាការនេះឃើញថា សំណុំរឿងនេះបានជំនុំជម្រះរួចម្តងហើយ ពេលនេះពិរុទ្ធជនឈ្មោះ [redacted] ស្រួយ ហៅ មី បានប្តឹងទាស់ នឹងសាលក្រមព្រហ្មទណ្ឌលេខ២៤៦៧ "ឈ" ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៩ របស់សាលាដំបូងរាជធានីភ្នំពេញ ដោយសារសាលក្រមនេះផ្តន្ទាទោសទម្ងន់ សំណងរដ្ឋប្បវេណីមានចំនួនច្រើន ដូច្នេះតំណាងអយ្យការនៅតែរក្សាបទចោទប្រកាន់ដដែល និងទុកសិទ្ធិជូនលោកស្រីចៅក្រមពិនិត្យ និងសម្រេចតាមច្បាប់។

-លោកមេធាវី [redacted] ជាមេធាវីការពារក្តីឲ្យពិរុទ្ធជនឈ្មោះ[redacted] ស្រួយ ហៅ មី បានធ្វើសេចក្តីសន្និដ្ឋានថា រឿងហេតុដែលបានកើតឡើងកាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៧ នេះកូនក្តីរបស់ខ្លួនឈ្មោះ [redacted] ស្រួយ គឺពុំមានចេតនាទៅបង្ករបួសស្នាមជាមួយឈ្មោះ [redacted] តាំ ដូចការចោទប្រកាន់របស់ដើមបណ្តឹងរដ្ឋប្បវេណីទេ។ ក្នុងរឿងនេះកូនក្តីរបស់ខ្លួនកាលពីអង្គសវនាការលើកមុនក៏មិនមានវត្តមាននាពេលសវនាការ ហើយក៏ពុំមានមេធាវីការពារសិទ្ធិចូលរួមសវនាការដែរ ដោយឃើញពីសកម្មភាពក្នុងរឿងនេះគឺកូនក្តីរបស់ខ្លួនបានទៅសួរនាំដើមបណ្តឹងរដ្ឋប្បវេណីក្រោយម្តាយរបស់ខ្លួនបានរងគ្រោះហើមភ្នែកដោយសារត្រូវឈ្មោះ [redacted] តាំ វាយ ទើបទៅសួរនាំឲ្យដឹងពីមូលហេតុដែលវាយម្តាយរបស់គាត់នោះ ពុំមានចេតនាបង្កជាអំពើហិង្សាទេគ្រាន់តែជាការឈ្លោះទាស់ទែងគ្នាហើយវាគ្នាទៅវិញទៅមកតែប៉ុណ្ណោះ ហើយទាក់ទងនឹងភស្តុតាងដែលដើមបណ្តឹងរដ្ឋប្បវេណីបានដាក់ក្នុងពាក្យបណ្តឹងនេះ គឺជាភស្តុតាងដែលមានក្រោយកើតហេតុដែលកូនក្តីរបស់ខ្លួនបានលើកឡើងថា មិនបានឃើញដើមបណ្តឹងរដ្ឋប្បវេណីនោះគាត់មានត្រូវរបួសនៅកន្លែងណាទេ ទាក់ទងនឹងឯកសារមួយចំនួនដូចជាសំបុត្រពេទ្យការចំណាយចាយវាយទៅលើថ្នាំពេទ្យ ដូចដែលតាមការលើកឡើងរបស់ដើមបណ្តឹងរដ្ឋប្បវេណីនោះគឺមានភាពច្រើនហួសហេតុ ដែលគ្មានឯកសារណាបញ្ជាក់ដូចការចោទប្រកាន់នេះទេ។ ហេតុដូច្នេះឃើញថា កូនក្តីរបស់ខ្លួនគ្មានចេតនាក្នុងការប្រើហិង្សាទៅលើដើមបណ្តឹងរដ្ឋប្បវេណីនោះទេ។

-ពិរុទ្ធជនឈ្មោះ [redacted] ស្រួយ ហៅ មី បាននិយាយសំដីចុងក្រោយបង្អស់ថា: ស្នើសុំឲ្យតុលាការជួយលើកលែងទោសដល់រូបខ្លួនផង។

ក្រោយពីបានស្តាប់ចម្លើយរបស់ពិរុទ្ធជនឈ្មោះ [redacted] ស្រួយ ហៅ មី

ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] តាំ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឲ្យពិរុទ្ធជន

ក្រោយពីបានពិនិត្យលើភស្តុតាងឯកសារផ្សេងៗក្នុងសំណុំរឿង

ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

សំអាងហេតុ

១-ពាក្យសុំប្តឹងទាស់ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២២ របស់ពិរុទ្ធជនឈ្មោះ [redacted] ស្រួយ ហៅ មី ដែលប្តឹងទាស់នឹងសាលក្រមព្រហ្មទណ្ឌលេខ២៤៦៧"ឈ" ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៩ ធ្វើឡើងមានលក្ខណៈត្រឹមត្រូវតាមច្បាប់ តាមមាត្រា៣៦២ និងមាត្រា៣៦៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលតុលាការអាចលើកពាក្យសុំប្តឹងទាស់យកមកជំនុំជម្រះបាន។

២-សាលក្រមព្រហ្មទណ្ឌលេខ២៤៦៧ "ឈ" ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៩ របស់សាលាដំបូងរាជធានីភ្នំពេញ បានសម្រេច ៖ ១-ផ្តន្ទាទោសឈ្មោះ [redacted] **ស្រួយ ហៅ មី** ភេទប្រុស អាយុ ២៣ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ **៥(ប្រាំ)ឆ្នាំ** គិតពីថ្ងៃចាប់ខ្លួនបានតទៅ ពីបទ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចក្នុងផ្សារនាគមាស ផ្លូវលេខ២៣៤ កែងផ្លូវ២៣៩ សង្កាត់ផ្សារដើមគរ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោស តាមមាត្រា២១៨ នៃក្រមព្រហ្មទណ្ឌ។ ២-បង្គាប់ឲ្យចាប់ខ្លួន និងឃុំខ្លួនជនជាប់ចោទឈ្មោះ [redacted] **ស្រួយ ហៅ មី** ភេទប្រុស អាយុ ២៣ឆ្នាំ ជនជាតិខ្មែរ ដែលមានសាវតាជាតិនៅខាងលើយកផ្តន្ទាទោសតាមច្បាប់។ ៣-បង្គាប់ឲ្យជនជាប់ចោទឈ្មោះ [redacted] **ស្រួយ ហៅ មី** ភេទប្រុស អាយុ ២៣ឆ្នាំ ជនជាតិខ្មែរ សងសំណងផ្លែព្យាបាល និងជម្ងឺចិត្ត រួមទាំងការខាតបង់ពេលវេលា ទឹកប្រាក់សរុបចំនួន១០,០០០(មួយម៉ឺន)ដុល្លារអាមេរិក ឲ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] តាំ។ ការទាមទារលើសពីនេះច្រានចោល។

៣-ផ្អែកតាមការឆ្លើយបំភ្លឺរបស់ពិរុទ្ធជនឈ្មោះ [redacted] **ស្រួយ ហៅ មី** បានឆ្លើយថា ខ្លួនទទួលស្គាល់ថាពិតជាបានប្រព្រឹត្តអំពើហិង្សាដោយការវាយប្រតាយប្រតប់គ្នាជាមួយឈ្មោះ [redacted] តាំ មែន ប៉ុន្តែខ្លួនពុំមានខ្សែក្រវ៉ាត់ ឬកៅអី ទៅវាយលើឈ្មោះ [redacted] តាំ ទេ គឺពួកខ្លួនប្រតាយប្រតប់គ្នាទៅវិញទៅមកដោយដៃនឹងដៃ ហើយមូលហេតុក៏ដោយសារឈ្មោះ [redacted]តាំ វាយម្តាយរបស់ខ្លួនបណ្តាលឲ្យហើម និងជាំភ្នែកមុន ទើបខ្លួនទៅសួរនាំក៏បង្កឲ្យកើតមានជាអំពើហិង្សានេះ ដែលចម្លើយសារភាពនេះបញ្ជាក់ថា ពិរុទ្ធជនពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន។

៤-បានឃើញកំណត់ហេតុប្រគល់-ទទួលប្រាក់ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៨ ចំនួន៣,០០០(បីពាន់) ដុល្លារអាមេរិក។

៥-អំពើរបស់ពិរុទ្ធជនធ្វើឲ្យប៉ះពាល់ដល់បូរណភាពរាងកាយអ្នកដទៃ និងសណ្តាប់ធ្នាប់សាធារណៈ រៀបរៀបរយល្អក្នុងសង្គម ដែលច្បាប់ហាមឃាត់ ជាពិសេសបានបំពានទៅនឹងមាត្រា២១៨ នៃក្រមព្រហ្មទណ្ឌ ដែលបានបញ្ជូតិឲ្យផ្តន្ទាទោសពី ២(ពីរ)ឆ្នាំ ទៅ ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី ៤,០០០,០០០(បួនលាន)រៀល ទៅ ១០,០០០,០០០ (ដប់លាន)រៀល។

៦-ពិរុទ្ធជនឈ្មោះ [redacted] ស្រួយ ហៅ មី ជានីតិជនដែលមានសមត្ថភាពស្មារតីគ្រប់គ្រាន់ ក្នុងការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន ដែលបានប្រព្រឹត្ត។

៧-ពុំមានហេតុផលណាក្រៅពីហេតុផលនៅក្នុងសាលក្រមព្រហ្មទណ្ឌលេខ២៤៦៧ "ឈ" ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៩ នោះឡើយ ហេតុនេះតុលាការគប្បីរក្សាទុកនូវសាលក្រមព្រហ្មទណ្ឌលេខ២៤៦៧ "ឈ" ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៩ ទុកជាបានការពេញទាំងមូល តែគប្បីកែប្រែត្រង់ការប្រកាសមូលទោសចំណុចទី១ និងចំណុចទី៣។

៨-ពិរុទ្ធជនឈ្មោះ [redacted] ស្រួយ ហៅ មី ត្រូវបានសមត្ថកិច្ចអនុវត្តដីកាបង្គាប់ឲ្យចាប់ខ្លួន និងឃុំខ្លួន៦៥៧ "ឈ" ដ.ច.ន ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៩ កាលពីថ្ងៃទី៣០ ខែមករា ឆ្នាំ២០២២ រួចរាល់ហើយ។

៩-តាមសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ នាពេលសវនាការដោយបានលើកថា សុំរក្សាបទចោទប្រកាន់ និងទុកសិទ្ធិជូនចៅក្រមជំនុំជម្រះពិនិត្យ និងសម្រេចតាមច្បាប់នោះ យើងបានពិចារណារួចហើយ។

១០-តាមសេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យពិរុទ្ធជន នាពេលសវនាការបានលើកឡើងថាកូនក្តីខ្លួនគ្មានចេតនាប្រព្រឹត្តអំពើហិង្សាលើដើមបណ្តឹងរដ្ឋប្បវេណីនោះ យើងបានពិចារណារួចហើយ។

១១-តាមសំដីចុងក្រោយរបស់ពិរុទ្ធជននោះ យើងបានពិចារណារួចហើយ។

ហេតុដូច្នេះ សម្រេច

១-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ២៤៦៧ "ឈ" ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៩ ទុកជាបានការដដែលលើកលែងតែចំណុចទី១ និងចំណុចទី៣ ត្រូវបានកែប្រែសម្រេចជាថ្មី ៖

ទី១(ថ្មី)-ផ្តន្ទាទោសឈ្មោះ [redacted] **ស្រួយ ហៅ មី** ភេទប្រុស កើតថ្ងៃទី១៧ ខែមេសា **ឆ្នាំ១៩៩៥** ជនជាតិខ្មែរ (សាវតាជាតិគ្រប់គ្រាន់) ដាក់ពន្ធនាគារកំណត់ **២(ពីរ)ឆ្នាំ** តែទោសនេះត្រូវអនុវត្តទោសពន្ធនាគារកំណត់ត្រឹមថិរវេលាដែលបានឃុំខ្លួនបណ្តោះអាសន្ន រីឯទោសនៅសល់ត្រូវអនុវត្តទោសព្យួរធម្មតា តាមមាត្រា១០៧ និងមាត្រា១០៨ នៃក្រមព្រហ្មទណ្ឌ។

ពីបទ: **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចក្នុងផ្សារនាគមាស ផ្លូវលេខ២៣៤ កែងផ្លូវ២៣៩ សង្កាត់ផ្សារដើមគរ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោស តាមបញ្ញត្តិមាត្រា**២១៨** នៃក្រមព្រហ្មទណ្ឌ។

ទី៣(ថ្មី)-បង្គាប់ឲ្យពិរុទ្ធជនឈ្មោះ [redacted] **ស្រួយ ហៅ មី** សងសំណងផ្តៃព្យាបាល និងជម្ងឺចិត្ត រួមទាំងការខាតបង់ពេលវេលាសរុបចំនួន៣,០០០(**បីពាន់**)**ដុល្លារអាមេរិក**។ ការទាមទារលើសពីនេះបដិសេធចោល។

២-សាលក្រមនេះជំនុំជម្រះជាសាធារណៈ នាថ្ងៃទី**២៥** ខែ**កុម្ភៈ** ឆ្នាំ**២០២២** និងប្រកាសជាសាធារណៈ នៅថ្ងៃទី**០១** ខែ**មីនា** ឆ្នាំ**២០២២** ចំពោះមុខពិរុទ្ធជនឈ្មោះ [redacted] **ស្រួយ ហៅ មី** និងកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **តាំ**។

ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

ក្រឡាបញ្ជីសវនាការ

ហត្ថលេខា និងត្រា

[redacted]

ចៅក្រមជំនុំជម្រះ

ហត្ថលេខា និងត្រា

[redacted]

បានឃើញ

ចៅក្រមជំនុំជម្រះ

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃចន្ទ ៥កើត ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២២

ក្រឡាបញ្ជី

[redacted]